ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

ក្រុមហ៊ុន ហ្គោថុន ត្រាវែល សឺវីស

និង

តំណាងកម្មករនិយោជិត

ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង ១០ និង ០០នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ហ្គោថុន ត្រាវែល សឺវីស មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងក្រុមហ៊ុនថា ដោយសារបញ្ហាជំងឺកូវីត១៩ (Covid-19) ដែលធ្វើអោយស្ថានភាពពិភពលោកទាំងមូលក៏ដូចជាព្រះរាជាណាចក្រកម្ពុជាយើងជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ធ្វើអោយភ្ញៀវទេសចរណ៍ទាំងអស់នៅលើពិភពលោកពុំអាចធ្វើដំណើរចេញក្រៅប្រទេស ធ្វើអោយក្រុមហ៊ុនពុំមានចំណូល ហើយបណ្តាក្រុមហ៊ុនមួយចំនួនធំនៅលើពិភពលោកត្រូវបានបិតទ្វារពុំមានចរាចរណ៍ឡើយ ហេតុដូចនេះក្រុមហ៊ុនបានសំរេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៩នាក់ (ស្រី ៦នាក់) ចំនួន០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥។ ដោយនៅក្នុងរំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនពុំមានលទ្ធភាពក្នុងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិកទាំងអស់នោះទេ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

សៀមរាប, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥

តំណាងកម្មករន និយោជិត

នាយកក្រុមហ៊ុន